ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ០៣/១១-សូឡារីស**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

**១- ភាគី ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល**

អាសយដ្ឋាន : អាគារលេខ ១៦៦ ផ្លូវលេខ ៤១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៨២ ៣៨០ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោកស្រី Dar Syluom General Manager

២- លោក ហុក សាខុន ប្រធានរដ្ឋបាល

**២- ភាគី បុគ្គលិក ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល**

អាសយដ្ឋាន : អាគារលេខ ១៦៦ ផ្លូវលេខ ៤១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៥៨ ៥៣២ ទូរសារ : គ្មាន

តំណាងភាគីបុគ្គលិក:

១- កញ្ញា ម៉ន វណ្ណតី ជំនួយការនាយិកា

២- Mr. Philippe Decaux Artistic Director

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ៣- Mr. Nicolas Bevillard | 3D Studio Director |
| ៤- កញ្ញា ខៀវ សុខចំរើន | 3D Studio |
| ៥- កញ្ញា ម៉ៅ បញ្ញា | 3D Studio |
| ៦- កញ្ញា ជាវីរៈ ស្រីល័ក្ខ | Finance Assistant |
| ៧- កញ្ញា យី ស៊ីធួន | បុគ្គលិកទីផ្សារ |
| ៨- កញ្ញា អ៊ុត ច័ន្ទមុនីតា | ប្រធានចែកចាយ |
| ៩- លោក សេង វិសុទ្ធ | 3D Studio |
| ១០- Mr. Loesener Joachim | 3D Manager |
| ១១- លោក អ៊ឹង សេងហាក់ | 3D Studio |
| ១២- លោក ខៀវ សុកផេន | 3D Studio |
| ១៣- លោក ពេជ រតនា | 3D Studio |
| ១៤- លោក អ៊ុក រដ្ឋា | 3D Studio |
| ១៥- លោកស្រី ស៊ុម ដាវី | អ្នកអាន |
| ១៦- Mr. Jan Mueller | Dubbing Director |
| ១៧- លោក សាន សារ៉ាត់ | 3D Studio |
| ១៨- លោក សាន់ សុភ័ក្រ្ត | Dubbing Speaker |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

បុគ្គលិកទាំងអស់នៅតែទាមទារប្រាក់ឈ្នួលដែលក្រុមហ៊ុនបានជំពាក់។ រីឯក្រុមហ៊ុននៅតែប្រកាន់ជំហរថា បើកប្រាក់ឈ្នួលតាមដំណាក់កាលក្នុងរយៈពេល ៨ ខែ ចំពោះបុគ្គលិកចំនួន ១២ នាក់ មាន Nicolas, Joachim, Sok Phen, Panha, Hak, Ratha, Sameth, Sok Chamroeun, Rothana, Sarath, Visoth, Rithy ដោយឡែកបុគ្គលិកដទៃទៀត ក្រុមហ៊ុនមិនទទួលខុសត្រូវបើកប្រាក់ឈ្នួលជូនទេ ព្រោះបុគ្គលិកទាំងនោះស្ថិតក្រោមការគ្រប់គ្រងរបស់លោក កែវ សុភាព ( អ្នកគ្រប់គ្រងទូរទស្សន៍អប្សរាជំនួសក្រុមហ៊ុន Solaris International ) ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ

នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៤) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៨០៣៨ មកបវ/អវក/វក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១ ។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ បានទទួលបណ្តឹងរបស់បុគ្គលិកក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ស្តីពីការទាមទារឱ្យក្រុមហ៊ុន សូឡារីស បើកប្រាក់ឈ្នួលឱ្យបុគ្គលិក ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ បានអញ្ជើញគូភាគីមកធ្វើការផ្សះផ្សាជាបន្តបន្ទាប់ និងផ្សះផ្សាលើកចុងក្រោយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ លើការទាមទារចំនួន ០១ ចំណុច ។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨០៣៨ មកបវ/អវក/វក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ១៤:00 នាទី រសៀល ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវព័ត៌មានបន្ថែម និងធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះដែរ ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងដោះស្រាយលើវិវាទនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូច ខាងក្រោមៈ

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន ។**

## ឯកសារ ទស្សនាវ ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

### ក- ឯកសារបានទទួលពីភាគីនិយោជក :

១- ប័ណ្ណប៉ាតង់ ឆ្នាំ២០១០ ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ ។

៣- លិខិតរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ជំរាបមកលោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន សូឡារីស ស្តីពីការសុំកែប្រែលក្ខន្តិកៈ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន សូឡារីស ។

៤- លក្ខន្តិកៈក្រុមហ៊ុន សូឡារីស ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ។

៥- ដីការសម្រេចរក្សាការពារលេខ ០៧ "ញ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ។

៦- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ អ៊ឹង សេងហាក់ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

៧- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ ខៀវ សុកផេន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

៨- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ សាន សារ៉ាត់ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

៩- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ ខៀវ សុខចំរើន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

១០- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ ម៉ៅ បញ្ញា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០

១១- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ អ៊ុក វឌ្ឍា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១០។

១២- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ អ៊ុក រិទ្ធី ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១០។

១៣- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ ស៊ឹម សាមេត ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

១៤- លិខិតសុំឈប់ពីការងារពីក្រុមហ៊ុន សូឡារីស របស់ឈ្មោះ ពេជ រតនា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

១៥- បង្កាន់ដៃបានទទួល ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ ។

THE ARBITRATION COUNCIL

១៦- លិខិតរបស់ក្រុមហ៊ុនសូឡារីស គោរពជូនលោក អគ្គនាយកស្ដីទីស្ថានីយ៍វិទ្យុ និងទូរទស្សន៍អប្សរា ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១០ ។

១៧- លិខិតរបស់ក្រុមហ៊ុនសូឡារីស ជំរាបជូនលោក Frank Dulac ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ។

១៨- លិខិតរបស់ក្រុមហ៊ុនសូឡារីស ជំរាបជូនលោក Jan Robet Mueller ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ។

១៩- លិខិតរបស់ក្រុមហ៊ុនសូឡារីស ជំរាបជូនលោក Lionel Cadiot ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ។

២០- លិខិតរបស់ក្រុមហ៊ុនសូឡារីស ជំរាបជូនកញ្ញា ម៉ម វណ្ណតី ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ។

២១- លិខិតរបស់ក្រុមហ៊ុនសូឡារីស ជំរាបជូនលោក Philippe Decaux ស្ដីពីការផ្ទេរបុគ្គលិក ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០ ។

២២- លិខិតក្រុមហ៊ុន សូឡារីស លេខ ០០១/១១ SI គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីការសុំបដិសេធរាល់ឯកសាររបស់បុគ្គលិកនិយោជិតស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍អប្សរា ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។

**ខ- ឯកសារបានទទួលពីភាគីបុគ្គលិក :**

១- លិខិតជ្រើសរើសអាជ្ញាកណ្ដាល ពីភាគីបុគ្គលិក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១។

២- ពាក្យបណ្ដឹងរបស់ឈ្មោះ Nicolas Bevillard គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣- ពាក្យបណ្ដឹងរបស់ឈ្មោះ Loesener Joachim គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤- ពាក្យបណ្ដឹងរបស់ឈ្មោះ ស៊ឹម សាម៉េត គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

៥- ពាក្យបណ្ដឹងរបស់ឈ្មោះ សេង វិសុទ្ធ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្ដីពីការទាមទារប្រាក់បៀវត្សដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

៦- ពាក្យបណ្តឹងរបស់ឈ្មោះ អ៊ុក រិទ្ធី គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ ។

៧- ពាក្យបណ្តឹងរបស់ឈ្មោះ អ៊ុក រដ្ឋា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

៨- ពាក្យបណ្តឹងរបស់ឈ្មោះ ខៀវ សុខចំរើន គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្សដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

៩- ពាក្យបណ្តឹងរបស់ឈ្មោះ ពេជ រតនា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្សដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

១០- ពាក្យបណ្តឹងរបស់ឈ្មោះ សាន សារ៉ាត់ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

១១- ពាក្យបណ្តឹងរបស់ឈ្មោះ ម៉ៅ បញ្ញា គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

១២- ពាក្យបណ្តឹងរបស់ឈ្មោះ ខៀវ សុកផេន គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

១៣- ពាក្យបណ្តឹងរបស់ឈ្មោះ អ៊ឹង សេងហាក់ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារប្រាក់បៀវត្ស ដែលក្រុមហ៊ុនជំពាក់ និងប្រាក់បន្ថែមលើការងារ ។

១៤- ពាក្យបណ្តឹងរបស់បុគ្គលិកក្រុមហ៊ុន សូឡារីស គោរពលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ ។

១៥- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន សូឡារីស ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ ។

១៦- ពាក្យបណ្តឹងរបស់ឈ្មោះ Yuma Antoine Decaux ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ស្តីពីការប្តឹង Mr. Edmord

Escabasse ប្រធានក្រុមហ៊ុន Asialis/Solaris International ដែលបើកប្រាក់ខែជូនបុគ្គលិក យឺតពេលវេលា និងមិនតាមកាលកំណត់ ។

១៧- ពាក្យបណ្ដឹងរបស់ឈ្មោះ Phillipe Decaux ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ស្ដីពីការប្ដឹង Mr. Edmord Escabasse ប្រធានក្រុមហ៊ុន Asialis/Solaris International ដែលបើកប្រាក់ខែជូនបុគ្គលិក យឺតពេលវេលា និងមិនតាមកាលកំណត់ ។

២៣- ដីការសម្រេចរក្សាការពារលេខ ០៧ "ញ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

២៤- បញ្ជីឈ្មោះបុគ្គលិកក្រុមហ៊ុន សូឡារីស ដែលទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួល ចំនួន ២៨ នាក់

២៥- ពាក្យបណ្ដឹងរបស់ឈ្មោះ ម៉ន វណ្ណតី ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ស្ដីពីការប្ដឹង Mr. Edmord Escabasse ប្រធានក្រុមហ៊ុន Asialis/Solaris International ដែលបើកប្រាក់ខែជូនបុគ្គលិក យឺតពេលវេលា ។

២៦- ពាក្យបណ្ដឹងរបស់ឈ្មោះ ម៉ន វណ្ណតី គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះខែធ្នូ ឆ្នាំ២០១០ ។

២៧- ពាក្យបណ្ដឹងរបស់ឈ្មោះ ម៉ន វណ្ណតី គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី០៧ ខែធ្នូ ។

២៨- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ យ៉ាន់ រ៉ូប៊ឺតម្ចូល័រ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ។

២៩- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ កែប សុផានណា ។

៣០- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ សូ ដារ៉ា ។

៣១- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ សាន់ សុភ័ក្រ្ត ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ។

៣២- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ ស៊ឹម ដាវី ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ។

៣៣- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ សួន ពន្លា ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ។

៣៤- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ តុល គន្ធា ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ។

៣៥- បញ្ជីរាយនាមបុគ្គលិកក្រុមហ៊ុនសូឡារីស អន្តរជាតិ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ។

៣៦- ដីការសម្រេចរក្សាការពារលេខ ០៧ "ញ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

THE ARBITRATION COUNCIL

៣៧- កិច្ចព្រមព្រៀងបន្ថែមស្តីពីសហប្រតិបត្តិការអភិវឌ្ឍន៍ស្ថានីយ៍វិទ្យុ និងទូរទស្សន៍អប្សរា និងក្រុមហ៊ុនសូឡារីស ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ។

៣៨- កិច្ចសន្យាការងារឈ្មោះ ហ្វីលីពឌើគូ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ។

៣៩- កិច្ចសន្យាការងារឈ្មោះ យូម៉ា អង់តែន ឌើគូ ។

៤០- កិច្ចព្រមព្រៀងផ្តល់ប្រាក់កំចី រវាងលោក Yuma Decaux ក្រុមហ៊ុន Asialis ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៩ ។

៤១- ពាក្យបណ្តឹងរបស់ឈ្មោះ ម៉ន វណ្ណតី គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៤២- កិច្ចសន្យាការងារឈ្មោះ លីអូណែល កាឌីយូត ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ។

៤៣- លិខិតបញ្ជាក់ការងាររបស់ឈ្មោះ លីអូណែលកាឌីយូត ។

៤៤- កិច្ចសន្យាការងារឈ្មោះ ហ្វ្រង់ ឌុយឡាក់ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩ ។

៤៥- បញ្ជីប្រាក់ខែសម្រាប់ខែមករា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៤៦- បញ្ជីប្រាក់ខែសម្រាប់ខែកុម្ភៈ ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៤៧- បញ្ជីប្រាក់ខែសម្រាប់ខែឧសភា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៤៨- បញ្ជីប្រាក់ខែសម្រាប់ខែមិថុនា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៤៩- បញ្ជីប្រាក់ខែសម្រាប់ខែកក្កដា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៥០- បញ្ជីប្រាក់ខែសម្រាប់ខែសីហា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៥១- បញ្ជីប្រាក់ខែសម្រាប់ខែកញ្ញា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៥២- បញ្ជីប្រាក់ខែសម្រាប់ខែតុលា ឆ្នាំ២០១០ របស់លោក ហ្វ្រង់ ឌុយឡាក់ ។

៥៣- កិច្ចសន្យាការងារឈ្មោះ យី ស៊ីធួន ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៩ ។

៥៤- បញ្ជីប្រាក់ខែសម្រាប់ខែកុម្ភៈ ឆ្នាំ២០១០ របស់លោក យី ស៊ីធួន ។

៥៥- បញ្ជីប្រាក់ខែសម្រាប់ខែមិថុនា ឆ្នាំ២០១០ របស់លោក យី ស៊ីធួន ។

៥៦- លិខិតប្តឹងក្នុងករណីបីពាក់ព័ន្ធនឹងឯកសារក្រុមហ៊ុន សូឡារីស ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១១ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល លេខ ៨០៣៨ មកបវ/អវក/វក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០២៧ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីបុគ្គលិកចូលរួមសវនាការលេខ ០២៨ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បង្កើតឡើងនៅក្នុងឆ្នាំ២០០៥ និងបានចុះកិច្ចព្រមព្រៀងសហការជាមួយស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា តាមរយៈកិច្ចព្រមព្រៀងចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦។ កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល និងស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា នឹងត្រូវផុតលត់នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៥។
- ចាប់តាំងពីឆ្នាំ២០០៦ រហូតមកដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ជាអ្នកគ្រប់គ្រងអាជីវកម្មស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ហើយមានជួលកម្មករនិយោជិតចំនួនប្រហែលជាង ១៨០ នាក់ ដែលក្នុងនោះមានកម្មករនិយោជិតដែលជាបុគ្គលិករបស់ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរាចំនួនប្រមាណ ៨០ នាក់ ហើយក្រៅពីនេះ គឺជាកម្មករនិយោជិតដែលរើសថ្មីដោយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ក្នុងអំឡុងពេលគ្រប់គ្រងអាជីវកម្ម។
- នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរក្សាការពារសម្រេចផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ទៅឱ្យស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា គ្រប់គ្រងជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី។
- នៅក្នុងសំណុំរឿងនេះ មានកម្មករនិយោជិតចំនួន ៣០ នាក់ ដែលជាភាគីដើមបណ្តឹងបានទាមទារឱ្យក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បើកប្រាក់ឈ្នួលដែលជំពាក់សម្រាប់កម្មករនិយោជិតចំនួន ៣០ នាក់ និងលោក យូម៉ា ដឹកូ។
- ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បានបញ្ជាក់ថា ក្រុមហ៊ុនទទួលស្គាល់តែកម្មករនិយោជិតចំនួន ១២ នាក់ ប៉ុណ្ណោះ ក្នុងចំណោមកម្មករនិយោជិតដែលទាមទារទាំងអស់ពីព្រោះ ក្រុមហ៊ុនបាន

ស្នើសុំទៅស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា រក្សាទុកផ្នែកចំនួន ០៣ គឺផ្នែកស្រ៊ុឌី ផ្នែកវេបសាយ និងផ្នែកបកប្រែតុលាការខ្មែរក្រហម ឱ្យបន្តនៅស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ដដែល ព្រោះ ផ្នែកទាំង៣នេះ មានសុទ្ធតែជាកម្មករនិយោជិតពិការ។ ការស្នើសុំគ្រប់គ្រងបន្តនេះ ព្រោះក្រុមហ៊ុនបារម្ភខ្លាចស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា មិនទទួលយកកម្មករនិយោជិតទាំងនោះឱ្យបំរើការងារ។ រហូតមកដល់ពេលបច្ចុប្បន្នផ្នែកទាំង ០៣ នេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ដដែល។

- ភាគីក្រុមហ៊ុន និងកម្មករនិយោជិតឯកភាពគ្នាថា ចាប់តាំងពីដីកាសម្រេចរក្សាការពារចេញមក អ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា បានចាក់សោរបិទទុកមិនឱ្យកម្មករនិយោជិតរបស់ក្រុមហ៊ុន សូឡារីស ចូលធ្វើការទេ។
- ភាគីក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បានបញ្ជាក់ថា ចាប់តាំងពីដីកាសម្រេចរក្សាការពារចេញមកដល់ បច្ចុប្បន្ននេះ ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ជាអ្នកគ្រប់គ្រងលើអាជីវកម្ម និងរាល់ចំណូលចំណាយទាំងអស់របស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល លើកលែងតែផ្នែកទាំង៣ខាងលើដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ដដែល។ ជាគោលការណ៍ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ត្រូវទទួលទាំងបំណុលផងដែរ។ ដូច្នេះ ប្រាក់ខែដែលជំពាក់កម្មករនិយោជិតទាំងអស់ក៏ត្រូវជាបន្ទុករបស់ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ព្រោះស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ជាអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ដោយរង់ចាំតុលាការសម្រេចដល់អង្គសេចក្ដី។
- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញនូវដីការសម្រេចរក្សាការពារ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ត្រង់ចំណុច "ហេតុដូច្នេះសម្រេចចំណុចទី២ : បង្គាប់ឱ្យកូនបំណុល ក្រុមហ៊ុន សូឡារីស អន្តរជាតិ :
  - ក- ប្រគល់ការគ្រប់គ្រងចលនវត្ថុទាំងអស់របស់ក្រុមហ៊ុន សូឡារីស អន្តរជាតិ ដែលបំពាក់ក្នុងស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ឱ្យម្ចាស់បំណុល *"ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា"*
  - ខ- ប្រគល់ការគ្រប់គ្រងអាជីវកម្មរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ឱ្យម្ចាស់បំណុល *"ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា"*

**<u>ករណីកម្មករនិយោជិតចំនួន ១២ នាក់ ដែលទទួលស្គាល់ដោយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មានឈ្មោះ ដូចខាងក្រោម:</u>**

| លេខរៀង | ឈ្មោះ | មុខងារ | ចូលបំរើការងារ | ចំនួនទឹកប្រាក់ជំពាក់ គិតជាប្រាក់ដុល្លារអាមេរិក |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | សាន សាវ៉ាត់ | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ២ | ខៀវ សុខចំរើន | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ៣ | ពេជ រតនា | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ៤ | ស៊ីម សាម៉េត | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ៥ | អ៊ឹង សេងហាក់ | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ៦ | លូសេណា ជូជឹង | អ្នកគ្រប់គ្រង ស្រ៊ីឌី | ០១/០៨/២០១០ | ១.៨០០ |
| ៧ | អ៊ុក រដ្ឋា | ស្រ៊ីឌី | ០១/០៨/២០០៨ | ១៨០ |
| ៨ | អ៊ុក រិទ្ធី | ស្រ៊ីឌី | ០១/០៨/២០០៨ | ១៨០ |
| ៩ | សេង វិសុទ្ធ | ស្រ៊ីឌី | ០១/០៨/២០០៨ | ១៨០ |
| ១០ | ម៉ៅ បញ្ញា | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ១១ | សុខផេង | ស្រ៊ីឌី | ០១/០១/២០០៨ | ១៨០ |
| ១២ | បេរីឡាត នី កូឡាស់ | ក្រាហ្វិក ឌីហ្សាញនីរ | ០១/០៩/២០០៩ | ១.៥០០ |

- ភាគីក្រុមហ៊ុន សូឡារីសអ៊ិន ធើណេសិនណល បានបញ្ជាក់ថា បច្ចុប្បន្ននេះ កម្មករនិយោជិតទាំង ១២ នាក់នេះ បំរើការងារនៅផ្នែកស្រ៊ីឌី ផ្នែកវេបសាយ និងផ្នែកបកប្រែតុលាការខ្មែរក្រហម។ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនពិតជាបានជំពាក់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតចំនួន ១២ នាក់នេះមែន ហើយស្នើសុំបង់រំលស់ក្នុងរយៈពេល ៨ ខែ ពីព្រោះ ក្រុមហ៊ុនកាន់តែមានភាពលំបាកផ្នែកហិរញ្ញវត្ថុ ដោយសាររាល់ចំណូលទាំងអស់របស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ត្រូវបានគ្រប់គ្រងដោយស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា។ ដូចនេះ ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មិនមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ជូនកម្មករនិយោជិតនោះទេ។
- ភាគីកម្មករនិយោជិតទទួលស្គាល់ស្ថានភាពលំបាករបស់ក្រុមហ៊ុន និងស្នើសុំឱ្យក្រុមហ៊ុនបង់ប្រាក់ឈ្នួលដែលជំពាក់នោះក្នុងរយៈពេល ៣ ខែ។ ភាគីកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់មិនអាចរង់ចាំរហូតដល់រយៈពេល ៨ ខែនោះទេ ដោយសារពួកគាត់ត្រូវចំណាយច្រើនទៅលើការហូបចុក និងការរស់នៅ ដូចនេះ គាត់ត្រូវការប្រាក់ខែរបស់គាត់។

THE ARBITRATION COUNCIL

**ករណីកម្មករនិយោជិតចំនួន ១៨ នាក់ ដែលមិនទទួលស្គាល់ដោយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មាន ឈ្មោះ ដូចខាងក្រោម :**

- នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតចំនួន ១៨ នាក់ ទាមទារឱ្យក្រុមហ៊ុន សូឡារីស បើកប្រាក់ឈ្នួលដែលជំពាក់ដល់ពួកគាត់។ កម្មករនិយោជិតដែលធ្វើការទាមទារឱ្យនិយោជកសងប្រាក់ឈ្នួលនោះ មានឈ្មោះរាយនាម ដូចខាងក្រោម:

| លេខរៀង | ឈ្មោះ | មុខងារ | ចូលបំរើការងារ | ចំនួនទឹកប្រាក់ជំពាក់ គិតជាប្រាក់ដុល្លារអាមេរិក |
|---|---|---|---|---|
| ១ | ហ្វីលីព ជីកូ | នាយកអាគធីស្តិក | ០១/០៨/២០០៩ | ៣៧.៦០៣ |
| ២ | យូម៉ា អង់តែន ជីកូ | នាយកស្រ៊ីឌី | ២៧/០៩/២០០៧ | ១៧.៥០០ |
| ៣ | ម៉ន វណ្ណតី | អ្នកបកប្រែអង់គ្លេសខ្មែរ | ២២/០១/២០១០ | ១.៥០០ |
| ៤ | លីយ៉ូនែល កាឌីយូ | នាយកផ្នែកទីផ្សារ | ០១/០៨/២០០៩ | ១៤.៣៣៨ |
| ៥ | ហ្វ្រង់ ឌុយឡាក់ | នាយកធនធានមនុស្ស | ០១/០៨/២០០៧ | ១៦.៩៨០ |
| ៦ | យី ស៊ីធួន | បុគ្គលិកផ្នែកទីផ្សារ | ០១/១០/២០០៧ | ១.៨៤០ |
| ៧ | ជា វិរៈស្រីល័ក្ខ | ជំនួយការគណនេយ្យ | ២៧/០៧/២០០៩ | ៣០០ |
| ៨ | អុត ចាន់មុន្នីកា | ប្រធានផ្នែកទីផ្សារ | ១៨/០៨/២០០៨ | ១៥០ |
| ៩ | យ៉ាន់ មូលើរ | ជំនួយការគណនេយ្យ | ២៥/០៣/២០០៧ | ៩.៥១៨ |
| ១០ | សូ ដារា | ជំនួយការផ្នែកបញ្ចូលសំលេង | មិនបានបញ្ជាក់ | ១.៦២០ |
| ១១ | ស៊ឹម ដារី | អ្នកបញ្ចូលសំលេង | ១១/០៦/២០០៧ | ២០០ |
| ១២ | សាន់ សុភ័ក្រ | អ្នកបញ្ចូលសំលេង | ១២/០១/២០០៩ | ៣១០ |
| ១៣ | សួន ពន្លា | អ្នកបញ្ចូលសំលេង | ០១/០៨/២០០៩ | ៥០០ |
| ១៤ | កែប សុផាណា | អ្នកបញ្ចូលសំលេង | ១២/០១/២០០៩ | ២៥០ |
| ១៥ | តុល គន្ធា | អ្នកបញ្ចូលសំលេង | ១២/០១/២០០៩ | ៥០០ |

| | | | | |
|---|---|---|---|---|
| ១៦ | ឡាយ ណូរ៉ា | សន្តិសុខ | ០១/០១/២០០១ | ២៨០ |
| ១៧ | ឃឹម សុខឃឿន | អ្នកសំអាត | ០១/០៤/២០០៩ | ២០០ |
| ១៨ | គល់ សុភ័ក្រ | អ្នកបើកឡាន | ០២/០៣/២០០៨ | ២២០ |

- ភាគីក្រុមហ៊ុនបានធ្វើការឆ្លើយតបនឹងការទាមទាររបស់កម្មករនិយោជិតខាងលើថា កម្មករនិយោជិតចំនួន ១៨ នាក់នេះ មិនមែនជាកម្មករនិយោជិតរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ទៀតទេ ចាប់តាំងពីដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ ២០១០ មក។
- ភាគីក្រុមហ៊ុនបានបន្តថា ដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន សូឡារីសអ៊ិនធើណេសិនណល ទៅឱ្យស្ថានីយវិទ្យុ និង ទូរទស្សន៍អប្សរាគ្រប់គ្រង ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី។ ដូចនេះ កម្មករនិយោជិតទាំងអស់របស់ សូឡារីស អ៊ិនធើណេសិនណល ក៏ស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នរបស់ស្ថានីយវិទ្យុ និង ទូរទស្សន៍អប្សរាដែរ។
- ភាគីក្រុមហ៊ុនបន្តថា នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១០ ក្រុមហ៊ុនបានសសេរលិខិតជូនទៅស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ដោយធ្វើការផ្ទេរបុគ្គលិកទាំងអស់របស់សូឡារីសអ៊ិនធើណេសិនណល ដែលកំពុងមាននាពេលបច្ចុប្បន្ន ដោយលិខិតនោះ មានការចុះហត្ថលេខាទទួលពីលោក កែវ សុភាព (ជាអគ្គនាយកស្តីទីស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា) លើបង្កាន់ដៃបានទទួល ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ពួកគាត់ចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល។ ដូចនេះ ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល គ្មានសិទ្ធិផ្ទេរពួកគាត់ឱ្យទៅស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ដោយមិនមានការឯកភាពពីពួកគាត់នោះទេ។ ភាគីក្រុមហ៊ុនបានឯកភាពថា កម្មករនិយោជិតទាំងនោះពិតជាបានចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មែន ប៉ុន្តែ បានបញ្ជាក់ថា ក្រុមហ៊ុនបានជូនដំណឹងទៅបុគ្គលិករួចរាល់អស់ហើយអំពីការផ្ទេរបុគ្គលិកនេះ។ ជាក់ស្តែងការជូនដំណឹងត្រូវបានធ្វើឡើង មុនថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០ ក្រោយពេលដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ ចេញនាថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលឯកសារភស្តុតាងពីភាគីនិយោជក នាថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១១ រកឃើញថា ក្រុមហ៊ុន សូឡារីស បានធ្វើការជូនដំណឹងទៅកម្មករនិយោជិតទាក់ទងនឹងការដាក់ពួកគាត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងជាបណ្តោះអាសន្នដោយស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា

ជាក់ស្តែងកម្មករនិយោជិតឈ្មោះ ម៉ម វណ្ណតី និងឈ្មោះ ហ៊ីលីព ជីកូ ត្រូវបានក្រុមហ៊ុនជូនដំណឹង នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ដោយមានកម្មករនិយោជិត ម៉ម វណ្ណតី និង ហ៊ីលីព ជីកូ ចុះហត្ថលេខាទទួលការជូនដំណឹងនេះ។ ភស្តុតាងនេះ មិនត្រូវបានជំទាស់ពីភាគីកម្មករនិយោជិតនោះទេ

**ករណីលោក យូម៉ា :**

- ភាគីកម្មករនិយោជិតក៏បានទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ដល់កម្មករនិយោជិតឈ្មោះ យូម៉ា ដែរ ប៉ុន្តែក្រុមហ៊ុនមិនឯកភាពទេ។
- លោក យូម៉ា ជីកូ បានចូលកាន់តំណែងជានាយកស្រ៊ីឌី ស្ទូឌីយូ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ ប៉ុន្តែបានក្លាយជាជនពិការភ្នែក នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ដោយគ្រោះថ្នាក់នាពេលវិស្សមកាលរបស់គាត់។
- នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ លោក យូម៉ា បានប្រកាសថា គាត់នឹងធ្វើការកន្លះថ្ងៃ ដោយទទួលប្រាក់ខែពាក់កណ្តាល។
- នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ លោក យូម៉ា ជីកូ បានលាឈប់ពីការងារ។
- ភាគីនិយោជកបានលើកឡើងថា គាត់មិនទទួលស្គាល់ការជំពាក់ប្រាក់ចំពោះកម្មករនិយោជិតរូបនេះទេ ពីព្រោះ គាត់បានលាឈប់ពីការងារទៅហើយ។ លោកនាយកចាស់របស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល គឺលោក អេតមិន បានទូទាត់ប្រាក់ខែដែលជំពាក់ជូនលោក យូម៉ា រួចរាល់ហើយដែរ។ ភាគីកម្មករនិយោជិតបានជំទាស់នូវឯកសារជាសារអេឡិចត្រូនិច ដែលជាសារឆ្លើយឆ្លងគ្នារវាងលោក យូម៉ា និងលោក អេតមិន តាមរយៈលិខិតជំទាស់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ដោយបញ្ជាក់ថា ក្រុមហ៊ុនបកប្រែឯកសារនោះតែពីរ ទៅបីបន្ទាត់តែប៉ុណ្ណោះ ហើយការបកប្រែនេះទៀតសោតជាការបកប្រែដោយការិយាល័យរបស់ខ្លួនឯង ដោយនាំឱ្យមានភាពមិនអាចជឿជាក់បាន ។
- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យនិយោជកសងប្រាក់ដែលជំពាក់ដល់លោក យូម៉ា សរុបចំនួន ១៧.៥០០ ដុល្លារអាមេរិក ដែលបានជំពាក់ប្រាក់ខែប្រចាំខែ កុម្ភៈ ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ ២០១០។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យនិយោជក និងភាគីកម្មករនិយោជិតដាក់ភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួន ដោយទុកពេលវេលាឱ្យគូភាគីធ្វើការបកប្រែឯកសារមកជាភាសាខ្មែរ និងរៀបចំដាក់ឯកសារផ្សេងទៀតដែលពាក់ព័ន្ធនានា ត្រឹមថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ដែលមានរយៈពេល

THE ARBITRATION COUNCIL

១០ ថ្ងៃ ក្រោយថ្ងៃសវនាការបានបញ្ចប់ និងធ្វើការជំទាស់លើភស្តុតាង នាថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១១។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ផ្អែកលើអង្គហេតុខាងលើមានកម្មករនិយោជិតចំនួន ៣០ នាក់ និងកម្មករនិយោជិតឈ្មោះ យូម៉ា ទាមទារឱ្យក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល សងប្រាក់ដែលឈ្នួលដែលក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បានជំពាក់ពួកគេ ប៉ុន្តែ ភាគីក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ទទួលស្គាល់តែកម្មករនិយោជិតតែចំនួន ១២ នាក់ទេ ចំណែកកម្មករនិយោជិត ១៨ នាក់ទៀត និងកម្មករនិយោជិតឈ្មោះ យូម៉ា ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មិនទទួលស្គាល់ទេ។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាថា តើក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មានកាតព្វកិច្ចទទួលខុសត្រូវលើបណ្តឹងទាមទារប្រាក់របស់កម្មករនិយោជិតចំនួន ៣០ នាក់ និងកម្មករនិយោជិតឈ្មោះ យូម៉ា នោះ ឬទេ?

**១.<u>ករណីកម្មករនិយោជិត ១២ នាក់</u> :**

យោងទៅតាមអង្គហេតុ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល បើកប្រាក់ខែដែលក្រុមហ៊ុនជំពាក់កម្មករនិយោជិតចំនួន ១២ នាក់ ក្នុងរយៈពេល ៣ ខែ ចំណែកក្រុមហ៊ុនសុំបើកប្រាក់ឈ្នួលដែលជំពាក់នោះឱ្យក្នុងរយៈពេល ៨ ខែ។

មាត្រា ១១៦ កថាខណ្ឌ២ នៃច្បាប់ស្តីពីការងារ បានចែងថា *" ប្រាក់ឈ្នួលនៃនិយោជិត ត្រូវបើកយ៉ាងហោចណាស់មួយដងក្នុងមួយខែ ។"*

យោងទៅតាមមាត្រាខាងលើ និយោជកមានកាតព្វកិច្ចត្រូវបើកប្រាក់ឈ្នួលឱ្យនិយោជិតរបស់ខ្លួន មួយខែម្តង។

នៅក្នុងសំណុំរឿងនេះ និយោជក គឺមិនបានអនុវត្តតាមកាតព្វកិច្ចនៃមាត្រា ១១៦ នេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការយឺតយ៉ាវរបស់និយោជក គឺដោយសារក្រុមហ៊ុនមានការលំបាកផ្នែកហិរញ្ញវត្ថុ។ កម្មករនិយោជិតផ្ទាល់ក៏ទទួលស្គាល់ថា និយោជកមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុដែរ។ នៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកមានជំហរនៅក្នុងការបង់រំលោះនូវប្រាក់ឈ្នួលដល់កម្មករនិយោជិត រីឯកម្មករនិយោជិតក៏មានជំហរក្នុងការទទួលយកនូវការបង់រំលោះដែរ។ ប៉ុន្តែ ភាគីនិយោជកស្នើសុំបង់ក្នុងរយៈពេល ៨ ខែ រីឯភាគីកម្មករនិយោជិតស្នើសុំបង់ក្នុងរយៈពេល ៣ ខែ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការស្នើសុំរបស់កម្មករនិយោជិតមានលក្ខណៈសមហេតុសមផល ព្រោះ ច្បាប់ការងារតម្រូវឱ្យនិយោជកបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតមួយខែម្តង ហើយករណីនេះ កម្មករនិយោជិមានការយោគយល់ចំពោះនិយោជករបស់ខ្លួនថែមទៀត ដោយសារក្រុមហ៊ុនមានបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុ។ ចំណែការលើកឡើងរបស់ក្រុមហ៊ុន ក្នុងការបង់

ARBITRATION COUNCIL

រំលោះប្រាក់ឈ្នួលរបស់កម្មករនិយោជិតរហូតដល់ ៨ ខែនេះ មានលក្ខណៈយូរពេកសម្រាប់កម្មករនិយោជិតដែលត្រូវការយកប្រាក់ឈ្នួលរបស់ពួកគាត់ទៅប្រើប្រាស់ ព្រោះតាមច្បាប់ និយោជកត្រូវបើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិត មួយខែម្តង។ ហេតុនេះ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោមៈ

ប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា " *ចំពោះបញ្ហាដែលបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមនេះមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទ........*

ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់ "

ផ្អែកលើខ្លឹមសារនៃប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីក្រុមហ៊ុនបង់ប្រាក់ដែលជំពាក់ជាបន្ទាន់ឱ្យទៅកម្មករនិយោជិតចំនួន ១២ នាក់ដែលទាមទារក្នុងសំណុំរឿងនេះ ប៉ុន្តែ ករណីនេះ ភាគីកម្មករនិយោជិតស្នើសុំឱ្យនិយោជកបង់រំលោះប្រាក់ឈ្នួលជូនកម្មករនិយោជិតក្នុងរយៈពេល ៣ ខែ យ៉ាងយូរ។ ហេតុនេះ ផ្អែកតាមប្រការ ៣៤ នៃប្រកាស ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេច ឱ្យនិយោជកបង់រំលោះប្រាក់ឈ្នួលជូនទៅកម្មករនិយោជិតចំនួន ១២ នាក់នេះ ក្នុងរយៈពេល ៣ ខែ។

**២.ករណីកម្មករនិយោជិត ១៨ នាក់ :**

នៅក្នុងករណីនេះ កម្មករនិយោជិតចំនួន ១៨ នាក់នេះ ទាមទារឱ្យក្រុមហ៊ុនសងប្រាក់ដែលក្រុមហ៊ុនបានជំពាក់មកកម្មករនិយោជិតវិញ។ ក្រុមហ៊ុនបញ្ជាក់ថា កម្មករនិយោជិតចំនួន ១៨ នាក់នេះ មិនមែនជាកម្មករនិយោជិតរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ទៀតទេ ចាប់តាំងពីពេលចេញដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ពោលគឺ ជាកម្មករនិយោជិតស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា។

មាត្រា ៨៧ នៃច្បាប់ស្តីពីការងារចែងថា " *កាលបើកែប្រែស្ថានភាពគតិយុត្តិនៃនិយោជក មានជាអាទិ៍ ដោយឧត្តរាធិការ "ការបន្តមរតក" ការលក់ការបញ្ចូលមូលនិធិ ឬការផ្លាស់ប្តូរមូលនិធិ ការដាក់ជាក្រុមហ៊ុននោះ កិច្ចសន្យាការងារទាំងឡាយដែលកំពុងប្រតិបត្តិមកដល់ថ្ងៃមានកែប្រែនោះ ត្រូវស្ថិតនៅដដែល រវាងនិយោជកថ្មី និងកម្មករនិយោជិតក្នុងសហគ្រាសគ្រឹះស្ថានចាស់។*

*ការរំលាយកិច្ចសន្យាអាចធ្វើទៅបានតែក្នុងទំរង់ និងល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងផ្នែក នេះស្រាប់។*

*ការបញ្ឈប់សកម្មភាពសហគ្រាសមិនបើកឱកាសឱ្យនិយោជកបានរួចអំពីកាតព្វកិច្ច ដែលមានចែងក្នុងផ្នែកទី៣ នេះទេ វៀរលែងតែក្នុងករណីប្រធានសក្តិ។ ធនក្ស័យ និងការជំរះបញ្ជីជាផ្លូវតុលាការ មិនត្រូវចាត់ទុកជាករណីប្រធានសក្តិទេ*

បើតាមអត្ថន័យនៃមាត្រា ៨៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ជាទូទៅការផ្លាស់ប្តូរស្ថានភាពគតិយុត្តិនៃនិយោជក វាមិនប៉ះពាល់ដល់កិច្ចសន្យាការងារទេ។ ( *សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៨/០៧-ស្កាយ ស៊ុណូ ហេតុផលចំណុចវិវាទទី១, លេខ ៨៣/០៨-ឡឺប្រ៉ង់ កាហ្វេ ហេតុផលចំណុចវិវាទទី១ និងទី២ និងលេខ ១០០/០៨-ហ្គារ័ន្ត អ៊ីភែរីល ហេតុផលចំណុចវិវាទទី១* )។

នៅក្នុងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១០០/០៨-ហ្គារ័ន្ត អ៊ីភែរីល ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា " *ការកែប្រែស្ថានភាពគតិយុត្តិនៃនិយោជក* " មានន័យថា *ជាការផ្លាស់ប្តូរបុគ្គលិកលក្ខណៈនៃនិយោជក ឬការផ្លាស់ប្តូរនិយោជក ឬនិយាយយ៉ាងសាមញ្ញថា ការផ្លាស់ប្តូរពីនិយោជក ដែលកំពុងមានបច្ចុប្បន្ន ទៅនិយោជកថ្មីមួយទៀត។ ហើយបើតាមមាត្រា២ នៃច្បាប់ស្តីពីការងារ និយោជកអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល។ ដូច្នេះ និយោជកដែលកំពុងមានបច្ចុប្បន្ន និងនិយោជកថ្មីអាចជារូបវន្តបុគ្គលផង ឬជានីតិបុគ្គលផង។ ហេតុនេះហើយ ករណីផ្លាស់ប្តូរនិយោជក គឺនិយោជកថ្មីអាចជារូបវន្តបុគ្គលថ្មីមួយ ឬក៏ជានីតិបុគ្គលបង្កើតថ្មីមួយ ឬក៏ជានីតិបុគ្គលចាស់ តែមានម្ចាស់ភាគហ៊ុនថ្មី ឬមានការថែម ឬថយចំនួនម្ចាស់ភាគហ៊ុន ដោយមានការប្រែប្រួលចំនួនភាគហ៊ុនតាមរូបភាពនៃការលក់ការបញ្ចូលមូលនិធិ ឬការផ្លាស់ប្តូរមូលនិធិ។* " ( *សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ ១០០/០៨-ហ្គារ័ន្ត អ៊ីភែរីល ហេតុផលចំណុចវិវាទទី១* )។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយខាងលើដែរ មានន័យថា ជាទូទៅ ការផ្លាស់ប្តូរស្ថានភាពគតិយុត្តិនៃនិយោជក វាមិនប៉ះពាល់ដល់កិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះទេ។

នៅក្នុងករណីនេះ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរក្សាការពារ ប្រគល់ការគ្រប់គ្រងចលនវត្ថុទាំងអស់របស់ក្រុមហ៊ុន សូឡារីស អន្តរជាតិ ដែលបំពាក់ក្នុងស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ឱ្យម្ចាស់បំណុល " *ស្ថានីយ៍វិទ្យុ និងទូរទស្សន៍អប្សរា* " និងប្រគល់ការគ្រប់គ្រងអាជីវកម្មរបស់ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរាឱ្យម្ចាស់បំណុល" *ស្ថានីយ៍វិទ្យុ និងទូរទស្សន៍អប្សរា* " ជាបណ្តោះអាសន្នរហូតដល់មានការសម្រេចអង្គសេចក្តី។

ដូច្នេះ ករណីនេះ មានការកែប្រែស្ថានភាពគតិយុត្តិនៃនិយោជកជាបណ្តោះអាសន្នតាមរយៈដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ ចាប់តាំងពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ដែលសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរក្សាការពារ សម្រេចផ្ទេរសិទ្ធិគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ទៅឱ្យស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា គ្រប់គ្រងជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តីមក។ ស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា ជាអ្នកគ្រប់គ្រងលើអាជីវកម្ម និងរាល់ចំណូលចំណាយទាំងអស់របស់ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល លើកលែងតែផ្នែកទាំង៣ ខាងលើដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល ដដែល។ ជាគោលការណ៍ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ត្រូវ

ទទួលទាំងបំណុលផងដែរ ទោះបីជាដីកាសម្រេចរក្សាការពារ គឺមិនមានការចែងច្បាស់លាស់ពីការទទួលយកនូវសិទ្ធិលើបំណុលនោះក៏ដោយ ។ ហើយបន្ថែមពីនេះ សាលាដំបូងរាជធានីភ្នំពេញក៏មិនទាន់ធ្វើសវនាការលើអង្គសេចក្តីនៅឡើយទេ។ ហេតុដូច្នេះហើយ នៅក្នុងរយៈពេលដែលមិនមានការសម្រេចលើអង្គសេចក្តីចំពោះករណីវិវាទរវាងស្ថានីយវិទ្យុ និងទូរទស្សន៍អប្សរា និងក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល នោះទេ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតទាំង ១៨ នាក់ ដែលទាមទារឱ្យក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល សងប្រាក់ឈ្នួលដែលជំពាក់មកខ្លួន រហូតដល់សាលាដំបូងរាជធានីភ្នំពេញ សម្រេចលើអង្គសេចក្តី ។

**៣. ចំពោះកម្មករនិយោជិតឈ្មោះ យូម៉ា :**

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមហ៊ុន សូឡារីស មានកាតព្វកិច្ចត្រូវសងប្រាក់ឈ្នួលដល់កម្មករនិយោជិតឈ្មោះ យូម៉ា ដែរ ឬទេ?

មាត្រា ១១៨ ច្បាប់ស្តីពីការងារ ជំពូកទី៦ ចំណុច គ-ការបើកប្រាក់ឈ្នួល ចែងថា " *ក្នុងករណីមានការប្តឹងជំទាស់អំពីរឿងប្រាក់ឈ្នួល គឺនិយោជកដែលជាអ្នកត្រូវផ្តល់ភស្តុតាងនៃការសងប្រាក់ឈ្នួលរួច ។ ភស្តុតាងនេះអាចជាហត្ថលេខានៃសាមីខ្លួនកម្មករនិយោជិត ឬសាក្សីពីរនាក់ ប្រសិនបើកម្មករនិយោជិតមិនចេះអក្សរ បានចុះក្នុងសៀវភៅបើកប្រាក់ ដែលនិយោជកមានកាតព្វកិច្ចរក្សាទុក ។* "

នៅក្នុងសំណុំរឿងលេខ ៦២/០៨-ប៉ាវដា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ១១៨ នៃច្បាប់ស្តីពីការងារ ខាងលើថា " *និយោជកជាអ្នកដែលត្រូវផ្តល់ភស្តុតាងនៃការបង់ប្រាក់ឈ្នួលរួច ។* "

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយខាងលើដែរ ហើយក្នុងករណីនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា ក្រុមហ៊ុន សូឡារីស អ៊ិនធើណេសិនណល មិនទាន់បានផ្តល់ប្រាក់ខែដែលជំពាក់សរុបចំនួន ១៧.៥០០ ដុល្លារអាមេរិក ប្រចាំខែកុម្ភៈ ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០១០ ជូនលោក យូម៉ា នៅឡើយទេ។ ចំណែកភាគីនិយោជកវិញ បានលើកឡើងថា លោក យូម៉ា បានទទួលប្រាក់ដែលក្រុមហ៊ុនបានផ្តល់រួចហើយ។ ដូចនេះ បើយោងតាមមាត្រា ១១៨ នៃច្បាប់ស្តីពីការងារ និងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើ ភាគីនិយោជកជាអ្នកដែលត្រូវផ្តល់ភស្តុតាង ដើម្បីបញ្ជាក់ថាខ្លួនពិតជាបានបង់ប្រាក់ឈ្នួលប្រចាំខែកុម្ភៈ ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០១០ ជូនលោក យូម៉ា រួចហើយ ។

នៅពេលសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឱ្យភាគីនិយោជកដាក់ភស្តុតាង ដើម្បីបញ្ជាក់ថា ខ្លួនពិតជាបានបើកប្រាក់ឈ្នួលរួចរាល់ឱ្យលោក យូម៉ា រួចអស់ហើយ។ ភាគីនិយោជកបានដាក់ភស្តុតាងមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ដែលមានឯកសារមួយចំនួនជាភាសាបរទេស និងមិនត្រូវបានបក

THE ARBITRATION COUNCIL

ប្រែនោះទេ។ នៅពេលសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ប្រាប់ភាគីថា រាល់ឯកសារដែលពាក់ពន្ធ័ទាំងអស់ត្រូវបកជាភាសាខ្មែរ។

ប្រការ ២៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា"*ភាសាដែលត្រូវប្រើក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺ ភាសាខ្មែរ ។...*"

ដូចនេះ យោងតាម ប្រការ ២៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនពិចារណាលើឯកសារភស្តុតាងជាភាសាបរទេស ដែលក្រុមហ៊ុនដាក់ជូននោះទេ។

ម្យ៉ាងវិញទៀត ឯកសារជាភាសាខ្មែរដែលភាគីនិយោជកផ្តល់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនមានលក្ខណៈច្បាស់លាស់ ដើម្បីបញ្ជាក់ថា ខ្លួនពិតជាបានបើកប្រាក់ឈ្នួលជូនលោក យូម៉ា រួចរាល់ឡើយ។ ភាគីនិយោជកគួរតែបានផ្តល់ឯកសារភស្តុតាងជាភាសាខ្មែរ មានដូចជា ប័ណ្ណទទួលប្រាក់ឈ្នួល ដែលចុះហត្ថលេខាទទួលដោយលោក យូម៉ា ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿជាក់ថា លោក យូម៉ា ពិតជាបានទទួលប្រាក់ឈ្នួលទាំងនេះ។

សរុបសេចក្តីមកក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកមិនបានផ្តល់ភស្តុតាង ដើម្បីដោះបន្ទុកចំពោះការចោទប្រកាន់អំពីការមិនបានបង់ប្រាក់ឈ្នួលជូនកម្មករនិយោជិតឈ្មោះ យូម៉ា ឡើយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យភាគីនិយោជកសងប្រាក់ឈ្នួលប្រចាំខែកុម្ភៈ ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ ២០១០ ជូនកម្មករនិយោជិតឈ្មោះ យូម៉ា។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ :

## សម្រេច និង បង្គាប់

១- បង្គាប់ឱ្យនិយោជកបង់រំលោះប្រាក់ឈ្នួលជូនទៅកម្មករនិយោជិតចំនួន ១២ នាក់ ក្នុងរយៈពេល ៣ ខែ។

២- បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតទាំង ១៨ នាក់ ដែលទាមទារឱ្យក្រុមហ៊ុន ស្វូឡារីស អ៊ិនធើណេសិនណល សងប្រាក់ឈ្នួលដែលជំពាក់មកខ្លួន រហូតដល់សាលាដំបូងរាជធានីភ្នំពេញសម្រេចលើអង្គសេចក្តី ។

៣- បង្គាប់ឱ្យភាគីនិយោជកសងប្រាក់ឈ្នួលប្រចាំខែ កុម្ភៈ ខែកក្កដា ខែសីហា និងខែកញ្ញា ឆ្នាំ២០១០ ជូនកម្មករនិយោជិតឈ្មោះ យូម៉ា។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុំ សុន្ធី**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL